វិធាននៃនីតិវិធីការទូតអំពីធនធានទឹកទន្លេមេគង្គ



PNPCA

# នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង

www.mrcmekong.org



# តើគណៈកម្មការទន្លេមេគង្គ ជាអ្វី?

ទន្លេមេគង្គ ស្ថិតក្នុងចំណោមទន្លេធំជាងគេបំផុតលើពិភពលោក និងហូរកាត់ប្រទេសចំនួន ៦ ក្នុងតំបន់អាស៊ីអាគ្នេយ៍ ចាប់ពីប្រទេសចិន រហូតដល់ប្រទេសវៀតណាម។ ការគ្រប់គ្រងអាងទន្លេនេះ ឲ្យមាននិរន្តរភាព និងសមធម៌ គឺជាការប្រឈមមួយរបស់បណ្តាប្រទេសតាមដងទន្លេមេគង្គ ប៉ុន្តែវាក៏តំណាងឲ្យកាលានុវត្តភាពមួយសម្រាប់កិច្ចសហការផងដែរ។

**គណៈកម្មការទន្លេមេគង្គ** ដែលហៅជាភាសាអង់គ្លេសថា Mekong River Commission ឬ MRC គឺជាអង្គការអន្តររដ្ឋាភិបាលមួយ ដែលធ្វើការដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការសន្ទនា និងកិច្ចសហប្រតិបត្តិការ នៅអាងទន្លេមេគង្គក្រោម។ បង្កើតឡើងដោយកិច្ចព្រមព្រៀងឆ្នាំ ១៩៩៥ រវាងប្រទេសកម្ពុជា ឡាវ ថៃ និង វៀតណាម MRC ផ្តល់នូវចំណេះដឹងវិទ្យាសាស្ត្រ និងជំនាញបច្ចេកទេសយ៉ាងច្រើនអំពីការគ្រប់គ្រងធនធានទឹក និងជាវេទិកាមួយសម្រាប់កិច្ចការទូតអំពីធនធានទឹកដើម្បីគាំទ្រការចរចាអំពីបញ្ហាទឹក ក្នុងចំណោមប្រទេសទាំងបួន។ នៅក្នុងក្របខ័ណ្ឌច្បាប់ ដែលបានឯកភាពគ្នាប្រទេសទាំងបួន នៅតាមដងទន្លេនេះ ហើយដែលមានផលប្រយោជន៍ និងអាទិភាពជាតិខុសៗគ្នា ត្រូវពិភាក្សាអំពីតម្រូវការ និងបញ្ហាប្រឈមរបស់ខ្លួន ទាក់ទងនឹងការអភិវឌ្ឍ និងត្រូវចរចាអំពីការប្រើប្រាស់ធនធានទឹករួមគ្នាឲ្យបានប្រសើរជាងមុន សម្រាប់ជាប្រយោជន៍រួម និងប្រជាពលរដ្ឋចំនួន ៦៥ លាននាក់នៅក្នុងតំបន់នេះ។



កម្ពុជា ឡាវ ថៃ វៀតណាម

# តើ នីតិវិធីស្តីពីការជូនដំណឹង ការពិគ្រោះយោបល់ និងកិច្ចព្រមព្រៀង ជាអ្វី?

ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ MRC បានរៀបចំវិធាននៃនីតិវិធី ចំនួន ៥ ស្តីពី គុណភាពទឹក ការចែករំលែកទិន្នន័យ ការតាមដានលើការប្រើប្រាស់ទឹក ការរក្សាលំហូរទឹក និងកិច្ចសហប្រតិបត្តិការលើការប្រើប្រាស់ទឹក ដើម្បីគាំទ្រការអនុវត្ត កិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥។ វិធានមួយក្នុងចំណោមវិធានទាំងនោះគឺ **នីតិវិធីស្តីពី ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង** ដែលហៅជាភាសាអង់គ្លេសថា Procedures for Notification, Prior Consultation and Agreement ឬ PNPCA ដែលបានអនុម័ត កាលពីខែវិច្ឆិកា ឆ្នាំ ២០០៣។

PNPCA ជាបណ្តុំនៃដំណើរការដោយឡែកពីគ្នាចំនួន ៣ ដែលអនុវត្តដោយប្រទេសជាសមាជិករបស់ MRC សម្រាប់គម្រោងនានា ដែលប្រើប្រាស់ទឹកអាងទន្លេមេគង្គ ដែលអាចនាំឲ្យមានការផ្លាស់ប្តូរច្រើនដល់លំហូរទឹក ឬ គុណភាពទឹកលើទន្លេមេនៃទន្លេមេគង្គ។ គម្រោងបែបនេះ អាចរាប់បញ្ចូលទាំងគម្រោងបណ្តាញស្រោចស្រពខ្នាតធំ ថាមពលវារីអគ្គិសនី និងការផ្គត់ផ្គង់ទឹក។

នីតិវិធីនេះ ត្រូវបានបង្កើតឡើងសម្រាប់ធ្វើឲ្យការប្រើប្រាស់ធនធានទឹកមានកម្រិតសមស្របបំផុត និងដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន និងរបរចិញ្ចឹមជីវិត របស់សហគមន៍តាមដងទន្លេនេះទាំង នៅតំបន់ខ្សែទឹកខាងលើ និងតំបន់ខ្សែទឹកខាងក្រោម។





# តើត្រូវអនុវត្ត នីតិវិធី PNPCA ដោយរបៀបណា?

នៅក្រោមនីតិវិធី PNPCA រាល់គម្រោងប្រើប្រាស់ទឹក ត្រូវឆ្លងកាត់ដំណើរការណាមួយនៃដំណើរការ ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន ឬ កិច្ចព្រមព្រៀងជាក់លាក់។ ដំណើរការទាំងនេះ មិនពាក់ព័ន្ធនឹងការឯកភាព ឬ ជំទាស់ ចំពោះគម្រោងណាមួយដែលបានស្នើឡើងនោះឡើយ។ ផ្ទុយទៅវិញ PNPCA គឺជាយន្តការមួយដើម្បីជួយឲ្យមានកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ លើការប្រើប្រាស់ទឹក។



**ការជូនដំណឹង** តម្រូវឲ្យប្រទេសដែលជាអ្នក ស្នើគម្រោង ជូនដំណឹងពិស្តារអំពីគម្រោងនោះ ដល់ប្រទេសជាសមាជិកផ្សេងទៀត មុននឹងចាប់ផ្តើមអនុវត្តគម្រោងដែលស្នើឡើងនោះ។



**ការពិគ្រោះយោបល់ជាមុន** ពាក់ព័ន្ធនឹងដំណើរការនៃការវាយតម្លៃបច្ចេកទេស និងការពិគ្រោះយោបល់ជាផ្លូវការ ដែលមានរយៈពេលសរុបចំនួន ៦ ខែ។ ក្នុងរយៈពេលនេះ ប្រទេសជាសមាជិកដែលបានទទួលសេចក្តីជូនដំណឹង មានឱកាសធ្វើការវាយតម្លៃអំពីផលប៉ះពាល់ឆ្លងដែន ដែលអាចកើតមានទៅលើប្រព័ន្ធអេកូឡូស៊ី និងរបរចិញ្ចឹមជីវិត និងលើកអនុសាសន៍ជាវិធានការនានាដើម្បីដោះស្រាយបញ្ហាទាំងនោះ មុននឹងមានការប្រើប្រាស់ទឹក។



**កិច្ចព្រមព្រៀងជាក់លាក់** តម្រូវឲ្យមានការចរចាហ្មត់ចត់ ដើម្បីឲ្យមានការឯកភាពជាឯកច្ឆ័ន្ទលើលក្ខខណ្ឌនានានៃសំណើគម្រោង ក្នុងចំណោមប្រទេសជាសមាជិកទាំងអស់ មុននឹងមានការប្រើប្រាស់ទឹកតាមការស្នើឡើង។

ការអនុវត្តដំណើរការនីមួយៗនៃដំណើរការទាំងបី នេះ អាចខុសគ្នា អាស្រ័យលើកត្តាបីប្រភេទនៃការប្រើប្រាស់ទឹក៖ **ប្រភេទទន្លេ** (ទន្លេមេ ឬ ដៃទន្លេ) **រដូវ** (ប្រាំង ឬ វស្សា) និង **វិសាលភាពនៃការប្រើប្រាស់ទឹក** (រវាងអាងទន្លេ និងនៅក្នុងអាងទន្លេ)។ តាមធម្មតា គម្រោងលើដងទន្លេមេ តម្រូវឲ្យមានដំណើរការស្មុគស្មាញជាងគម្រោងនៅលើដៃទន្លេ។ ការប្រើប្រាស់ទឹកនៅរដូវប្រាំង ទាមទារឲ្យមានដំណើរការហ្មត់ចត់ជាងការប្រើប្រាស់ទឹកនៅរដូវវស្សា។ ដូចគ្នានេះដែរ ការបង្វែរទឹករវាងអាងទន្លេ ដែលជាការបង្វែរទឹកពីអាងទន្លេមេគង្គ ទៅអាងទន្លេណាមួយផ្សេងទៀត ទាមទារឲ្យមានដំណើរការហ្មត់ចត់ ជាងការប្រើប្រាស់នៅក្នុងអាងទន្លេនេះ ដែលពុំមែនជាការបង្វែរចេញពីអាងទន្លេមេគង្គ។ តារាងខាងក្រោមបង្ហាញពីកត្តាកំណត់នានា និងដំណើរការដែលត្រូវនឹងកត្តាកំណត់នីមួយៗ។

| ប្រភេទទន្លេ | រដូវ | វិសាលភាពនៃការប្រើប្រាស់ទឹក | នីតិវិធីចាំបាច់ |
|---|---|---|---|
| ទន្លេមេ | រដូវប្រាំង | រវាងអាងទន្លេ (ពីអាងទន្លេមេគង្គ ទៅអាងទន្លេណាមួយផ្សេងទៀត) | កិច្ចព្រមព្រៀងជាក់លាក់ |
| | | នៅក្នុងអាងទន្លេ (ក្នុងអាងទន្លេមេគង្គ) | ការពិគ្រោះយោបល់ជាមុន |
| | រដូវវស្សា | រវាងអាងទន្លេ (ពីអាងទន្លេមេគង្គ ទៅអាងទន្លេណាមួយផ្សេងទៀត) | ការពិគ្រោះយោបល់ជាមុន |
| | | នៅក្នុងអាងទន្លេ (ក្នុងអាងទន្លេមេគង្គ) | ការជូនដំណឹង |
| ដៃទន្លេ | ទាំងពីររដូវ | នៅក្នុងអាងទន្លេ (ក្នុងអាងទន្លេមេគង្គ) | ការជូនដំណឹង |

# តើ ការពិគ្រោះយោបល់ជាមុន ប្រព្រឹត្តទៅដោយរបៀបណា?

ដំណើរការពិគ្រោះយោបល់ជាមុន ធ្វើឡើងតាមជំហានមួយចំនួន អាស្រ័យទៅតាម នីតិវិធី PNPCA និង កិច្ចព្រមព្រៀងមេគង្គ។

**ជំហានទី ១** ប្រទេសជាសមាជិកដែល ស្នើគម្រោង ត្រូវជូនដំណឹងដល់លេខាធិការដ្ឋាន MRC អំពីចេតនារបស់ខ្លួនក្នុងការអនុវត្តដំណើរការពិគ្រោះយោបល់ជាមុន និងដាក់ជូនឯកសារគម្រោងពិស្តារ។ ក្នុងរយៈពេល ១ ខែ លេខាធិការដ្ឋាន MRC ត្រូវពិនិត្យឯកសារទាំងនោះ និងផ្ទៀងផ្ទាត់ភាពពេញលេញនៃឯកសារទាំងនោះ ដោយយោងទៅតាមវិធាននានា មុននឹងបញ្ជូនករណីនេះ ទៅ គណៈកម្មាធិការរួម ដែលជាស្ថាប័នគ្រប់គ្រងរបស់ MRC ដែលមានតំណាងមកពី រដ្ឋាភិបាលនៃប្រទេសជាសមាជិកទាំងបួន ហើយដែលការពិគ្រោះយោបល់នឹងធ្វើឡើងនៅកម្រិត គណៈកម្មាធិការរួមនេះ។

**ជំហានទី ២** ការពិគ្រោះយោបល់ជាមុន ចាប់ផ្តើមអនុវត្តនៅពេលដែលសមាជិកទាំងអស់នៃគណៈកម្មាធិការរួម បានទទួលសេចក្តីជូនដំណឹងដោយភ្ជាប់ជាមួយនូវឯកសារគម្រោង។ ក្នុងរយៈពេល ៦ ខែ គណៈកម្មាធិការរួម ធ្វើការពិនិត្យទិដ្ឋភាពបច្ចេកទេសនៃគម្រោង ដើម្បីកំណត់អនុលោមភាពជាមួយនីតិវិធីនានារបស់ MRC ស្តីពីរបបលំហូរ និងគុណភាពទឹក ធ្វើការវាយតម្លៃរាល់ផលប៉ះពាល់ដែលអាចកើតមានមកលើបរិស្ថាន និងរបរចិញ្ចឹមជីវិត និងលើកស្នើវិធានការដើម្បីដោះស្រាយកង្វល់ទាំងនោះ មុននឹងបិទបញ្ចប់ដំណើរការនេះ។

**ការវាយតម្លៃបច្ចេកទេស៖** ជាផ្នែកមួយនៃការវាយតម្លៃលើទិដ្ឋភាពបច្ចេកទេសដែលគណៈកម្មាធិការរួម តម្រូវឲ្យប្រទេសជាសមាជិក និងលេខាធិការដ្ឋាន MRC បង្កើតក្រុមការងារពិសេសមួយ ដើម្បីពិនិត្យទិដ្ឋភាពនានា ដូចជា សុវត្ថិភាពទំនប់ ចរាចរត្រី លំហូរកំណកកករ នាវាចរ និងផលប៉ះពាល់បរិស្ថាន និងសេដ្ឋកិច្ច-សង្គម។ ឧបករណ៍ និងគោលការណ៍ណែនាំនានា របស់ MRC ដែលរួមទាំង



*គោលការណ៍ណែនាំបឋម ស្តីពីគំរោងវិស្វកម្មសម្រាប់ទំនប់ដែលស្នើសាងសង់លើទន្លេមេ* មានតួនាទីជួយដល់ការវាយតម្លៃខាងបច្ចេកទេស។ ការធ្វើទស្សនកិច្ចនៅក្នុងទីតាំងគម្រោង ក៏ត្រូវធ្វើឡើងនៅក្នុងដំណាក់កាលនេះផងដែរ។

**ការពិគ្រោះយោបល់៖** ដើម្បីស្តាប់កង្វល់ និងទស្សនៈរបស់សាធារណជន និងភាគីដែលមានចំណាប់អារម្មណ៍ ការពិគ្រោះយោបល់នានា ទាំងនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ត្រូវរៀបចំឡើងដោយលេខាធិការដ្ឋាន MRC និងគណៈកម្មាធិការជាតិទន្លេមេគង្គ នៃប្រទេសជាសមាជិកនីមួយៗ ពោលគឺស្ថាប័នរដ្ឋាភិបាលដែលសម្របសម្រួលការងាររបស់ MRC នៅថ្នាក់ជាតិ។

**ជំហានទី ៣** នៅចុងបញ្ចប់នៃអំឡុងពេលពិគ្រោះយោបល់ គណៈកម្មាធិការរួម ត្រូវពិភាក្សាដើម្បីទទួលបានមតិជាឯកច្ឆ័ន្ទ អំពីលក្ខខណ្ឌនានាដែលគួរត្រូវអនុវត្តបន្ទាប់ សម្រាប់គម្រោងដែលបានស្នើឡើង។ កិច្ចព្រមព្រៀងនេះ ពុំមែនជាការឯកភាព ឬ ការជំទាស់ ចំពោះសំណើគម្រោងនោះឡើយ។ ផ្ទុយទៅវិញ ដំណើរការនេះ ត្រូវបានបង្កើតឡើង ដើម្បីអាចឲ្យប្រទេសដែលជាអ្នកបានទទួលសេចក្តីជូនដំណឹង មានឱកាសលើកអនុសាសន៍ និងដើម្បីឲ្យប្រទេសដែលជាអ្នកស្នើគម្រោងទទួលយកលក្ខខណ្ឌជាក់លាក់មួយចំនួន ដើម្បីកាត់បន្ថយរាល់ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន និងដើម្បីស្វែងរកវិធីប្រសើរជាងមុន សម្រាប់ការចែករំលែកផលប្រយោជន៍។ ប្រសិនបើគណៈកម្មាធិការរួម តម្រូវឲ្យមានពេលបន្ថែមទៀតសម្រាប់ការពិភាក្សា រយៈពេលសម្រាប់ការពិគ្រោះយោបល់ជាមុន ក៏អាចនឹងត្រូវពន្យាបន្ថែមផងដែរ។

**ជំហានទី ៤** នៅពេលដែលការពិគ្រោះយោបល់បានបញ្ចប់ហើយ ប្រទេសជាអ្នកស្នើគម្រោង អាចចាប់ផ្តើមអនុវត្តគម្រោងបាន។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើគណៈកម្មាធិការរួម មិនអាចឈានដល់ការព្រមព្រៀងគ្នាបានទេនោះ គណៈកម្មាធិការរួម អាចបញ្ជូនករណីនេះ ទៅក្រុមប្រឹក្សានៃ MRC ដែលជាស្ថាប័នធ្វើសេចក្តីសម្រេចជាន់ខ្ពស់បំផុតនៃអង្គការនេះ និងដែលមានសមាសភាពជារដ្ឋមន្ត្រីនៃប្រទេសជាសមាជិកទាំងបួន ដើម្បីធ្វើការដោះស្រាយ។

**ជំហានទី ៥** ប្រសិនបើក្រុមប្រឹក្សានេះមិនអាចដោះស្រាយកិច្ចការនេះបានទេ ករណីនេះ នឹងត្រូវបញ្ជូនទៅរដ្ឋាភិបាលពាក់ព័ន្ធ ដើម្បីដោះស្រាយតាមរយៈដំណើរការចរចាតាមផ្លូវទូតជាធម្មតា។



## ក្របខ័ណ្ឌនៃដំណើរការពិគ្រោះយោបល់ជាមុន




## តើ នីតិវិធី PNPCA ត្រូវបានអនុវត្ត ដោយរបៀបណា?

តាំងពីឆ្នាំ ១៩៩៥ មក រហូតដល់ចុងឆ្នាំ ២០១៦ MRC បានទទួលឯកសារ ដាក់ជូនសរុបចំនួន ៥៣ អំពីគម្រោងប្រើប្រាស់ទឹក នៅក្រោមកិច្ចព្រមព្រៀងមេគង្គ និងនីតិវិធី PNPCA នេះ។ ឯកសារចំនួន ៥០ ត្រូវបានដាក់ជូន សម្រាប់ការជូនដំណឹង ឯកសារចំនួន ៣ សម្រាប់ការពិគ្រោះយោបល់ជាមុន និងគ្មានឯកសារណាមួយ សម្រាប់កិច្ចព្រមព្រៀងដាក់លាក់ឡើយ។

ក្នុងចំណោមករណីនៃការជូនដំណឹង ទាំង ៥០ មាន ៤៥ ករណី ជាគម្រោងលើដៃទន្លេ និង ៥ ករណី ជាគម្រោងលើទន្លេមេ។ ក្នុងចំណោមគម្រោងទាំងនេះ មាន ៣៩ ជាគម្រោងថាមពលវារីអគ្គិសនី ហើយគម្រោងផ្សេងទៀត គឺសម្រាប់ការស្រោចស្រព ការដោះទឹក និងការត្រួតពិនិត្យទឹកជំនន់។ ប្រទេសឡាវ និងវៀតណាម បានដាក់ជូនគម្រោងភាគច្រើន សម្រាប់ជាការជូនដំណឹង។

គម្រោងនានាដែលបានដាក់ជូនសម្រាប់ការជូនដំណឹង រួមមាន គម្រោងថាមពលវារីអគ្គិសនី របស់កម្ពុជា ដែលស្នើសាងសង់លើទន្លេសេសាន ក្នុងខេត្តរតនគិរី នៅភាគឦសាននៃប្រទេសកម្ពុជា កាលពីឆ្នាំ ២០១០។ សំណើរបស់ប្រទេសថៃ នៅឆ្នាំ ១៩៩៥ សម្រាប់សិក្សាផែនការមួយដើម្បីបង្វែរទឹកពីទន្លេកុក និងទន្លេអ៊ីង ទៅអាងទន្លេចៅផ្រាយ៉ា ដែលស្ថិតក្នុងខេត្តឈៀងរ៉ៃ ផាយ៉ាវ និង ណាន នៅភាគខាងជើងនៃប្រទេសថៃ។ គម្រោងបណ្តាញស្រោចស្រពខ្នាតធំ ក្នុងខេត្តដាក់ឡាក់ នៅភាគកណ្តាលនៃប្រទេសវៀតណាម ដែលបានស្នើឡើងនៅឆ្នាំ ២០០៥។

នៅក្នុងអំឡុងពេលនេះដែរ មានករណីចំនួន ៣ សម្រាប់ការពិគ្រោះយោបល់ជាមុន ដែលទាក់ទងនឹងគម្រោងថាមពលវារីអគ្គិសនីលើដងទន្លេមេនៃទន្លេមេគង្គ នៅក្នុងប្រទេសឡាវ។ ករណីទី១ គឺ គម្រោងសាយ៉ាប៊ូរី ដែលជាគម្រោងទំនប់មិនបង្កើតជាអាងទឹក (run-of-river) ដែលមានសមត្ថភាព ១.២៨៥ មេហ្គាវ៉ាត់ ក្នុងខេត្តសាយ៉ាប៊ូរី នៅភាគខាងជើងនៃប្រទេសឡាវ។ ការជូនដំណឹងបានធ្វើឡើងនៅខែ កញ្ញា ឆ្នាំ២០១០ និងបានឆ្លងកាត់ការពិគ្រោះយោបល់រយៈពេល ៦ ខែ ចាប់ពីខែ តុលា ឆ្នាំ ២០១០ ដល់ខែ មីនា ឆ្នាំ ២០១១។

ករណីទី២ គឺ គម្រោង ដនសាហុង ដែលមានសមត្ថភាព ២៤០ មេហ្គាវ៉ាត់ ដែលត្រូវសាងសង់លើផ្លូវទឹកមួយនៅក្នុងតំបន់ស៊ីផានដន (កោះ៤០០០) នៃទន្លេមេគង្គ នៅជិតព្រំប្រទល់ប្រទេសឡាវ-កម្ពុជា។ ករណីនេះ ត្រូវបានដាក់ជូនជាលើកដំបូងសម្រាប់ដំណើរការនៃការជូនដំណឹង នៅខែ កញ្ញា ឆ្នាំ២០១៣ និងក្រោយមកត្រូវបានដាក់ជូនឡើងវិញសម្រាប់ការពិគ្រោះយោបល់ជាមុន នៅខែ មិថុនា ឆ្នាំ២០១៤ ហើយបានឆ្លងកាត់រយៈពេល ៦ ខែ នៃការពិគ្រោះយោបល់ជាមុន ចាប់ពីខែ កក្កដា ឆ្នាំ២០១៤ ដល់ខែ មករា ឆ្នាំ ២០១៥។

ករណីចុងក្រោយ ត្រូវបានដាក់ជូន នៅខែ វិច្ឆិកា ឆ្នាំ ២០១៦ ដែលជាគម្រោងទំនប់មិនបង្កើតជាអាងទឹក (run-of-river) ដែលគ្រោងសាងសង់នៅប៉ាក់បេង ក្នុងខេត្តឧត្តមសាយ នៅភាគខាងជើងនៃប្រទេសឡាវ។ ការពិគ្រោះយោបល់ជាមុនលើគម្រោងនេះបានចាប់ផ្តើម នៅខែ ធ្នូ ឆ្នាំ ២០១៦ និងត្រូវបន្តរហូតដល់ ខែ មិថុនា ឆ្នាំ ២០១៧។

| ការជូនដំណឹង | ការពិគ្រោះយោបល់ជាមុន | កិច្ចព្រមព្រៀងជាក់លាក់ |
|---|---|---|
| ៥០ ករណី | ៣ ករណី | ០ ករណី |



# តើ នីតិវិធី PNPCA នាំមកនូវលទ្ធផលអ្វីខ្លះ?

ដំណើរការពិគ្រោះយោបល់ជាមុន ចំនួន ២ ករណីដំបូង សម្រាប់គម្រោងសាយ៉ាប៊ូរី និង ដុនសាហុង គឺជាករណីសាកល្បងសម្រាប់កិច្ចការទូតនៃ MRC អំពីថាមពលវារីអគ្គិសនី។ នៅក្នុងដំណើរការទាំងពីរនេះ ប្រទេសជាសមាជិក និងលេខាធិការដ្ឋាន MRC បានអនុវត្តយ៉ាងហ្មត់ចត់ទៅតាមជំហាននានា ដែលមានចែងនៅក្នុងនីតិវិធីនេះ ប៉ុន្តែពុំបានឈានដល់ដំណោះស្រាយណាមួយឡើយ ទោះជានៅកម្រិតគណៈកម្មាធិការរួម ឬ នៅកម្រិតក្រុមប្រឹក្សាក៏ដោយ។

ទោះជាយ៉ាងណាក៏ដោយ ករណីទាំងពីរ បានផ្តល់ឱកាសដល់ប្រទេសជាសមាជិក អង្គុយជជែកគ្នា និងពិនិត្យមើលគម្រោងអភិវឌ្ឍន៍នៃប្រទេសដែលមានអធិបតេយ្យភាពនៅជិតខាងខ្លួន និងដើម្បីដោះស្រាយកង្វល់នានាអំពីដែនដី និងប្រជាពលរដ្ឋរបស់ខ្លួន។ ដំណើរការទាំងនេះក៏បានផ្តល់ផងដែរនូវភាពស្របច្បាប់សម្រាប់ភាគីផ្សេងទៀតដែលមានចំណាប់អារម្មណ៍ ក្នុងការបង្ហាញពីការព្រួយបារម្ភរបស់ខ្លួន។

នៅក្នុងករណី គម្រោងសាយ៉ាប៊ូរី ដំណើរការនេះបានតម្រូវឲ្យរដ្ឋាភិបាលឡាវ និងក្រុមហ៊ុនអភិវឌ្ឍន៍ទំនប់ធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថានរបស់ខ្លួន និងធ្វើការសម្រេចអំពីការវិនិយោគបន្ថែមចំនួន ៤០០លានដុល្លារអាមេរិក ដើម្បីកែសម្រួលប្លង់ទំនប់ ដើម្បីដោះស្រាយបញ្ហានានាទាក់ទងនឹងបញ្ហា ចរាចរត្រី និងកំណកកករ ពោលគឺ កង្វល់ចម្បងចំនួន ២ ដែលបានលើកឡើងនៅក្នុងពេលពិគ្រោះយោបល់ជាមុន។

ចាប់តាំងពីពេលនោះមក ទាំងប្រទេសជាសមាជិក និងលេខាធិការដ្ឋាន MRC បានពិនិត្យ និងពិភាក្សាទិដ្ឋភាពនានានៃ PNPCA ដើម្បីកែលម្អការអនុវត្តរបស់ខ្លួន ដែលរួមទាំង ភាពគ្រប់គ្រាន់នៃការរៀបចំឯកសារ និងថេរៈវេលានៃការចែករំលែកព័ត៌មាន។ មេរៀនទាំងនេះមួយចំនួន នឹងត្រូវដាក់បញ្ចូលនៅក្នុងដំណើរការពិគ្រោះយោបល់អំពីគម្រោងនានា នាពេលអនាគត។

# សម្រាប់ព័ត៌មានបន្ថែមអំពី PNPCA៖

សូមអាននៅក្នុងគេហទំព័ររបស់ **MRC**៖ www.mrcmekong.org

អំពីនីតិវិធីនានា៖ www.mrcmekong.org/publications/policies-procedures-and-guidelines/

អំពីការពិគ្រោះយោបល់ជាមុន៖ www.mrcmekong.org/topics/pnpca-prior-consultation/


## លេខាធិការដ្ឋាន MRC

P.O. Box 6101, Unit 18 ភូមិ Sithane Neua ស្រុក Sikhottabong ទីក្រុង វៀងច័ន្ទ សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ទូរស័ព្ទ៖ +856 21 263 263 ទូរសារ: +856 21 263 264

អ៊ីម៉ែល៖ mrcs@mrcmekong.org (សំណួរទូទៅ);
mrcmedia@mrcmekong.org (សំណួរសម្រាប់សារព័ត៌មាន)




© Mekong River Commission

ចេញផ្សាយនៅ ខែធ្នូ ឆ្នាំ២០១៦

ឯកសារនេះមានគោលដៅសម្រាប់ជាព័ត៌មានសាធារណៈ និងមិនមែនជាឯកសារនីតិវិធីផ្លូវការរបស់គណៈកម្មការទន្លេមេគង្គឡើយ

www.mrcmekong.org